# វាមិនដែលងាយស្រួលដូចពេលនេះទេ ដើម្បីទទួលបានការចាក់ថ្នាំបង្ការ!

## ថ្នាំបង្ការជំងឺ COVID-19 គឺឥតគិតថ្លៃ និងអាចរកបានសម្រាប់មនុស្សដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ!

- ថ្នាំបង្ការអាចរកបាននៅទីតាំងរាប់រយកន្លែងផ្សេងៗគ្នានៅទូទាំងខោនធី LA រួមមានគ្លីនិក ឱសថស្ថាន កន្លែងធ្វើការ សាលារៀន កន្លែងគោរពបូជា ស្ថានីយ៍រថភ្លើងក្រោមដី និងសួនឧទ្យាន។ នៅតាមទីតាំងជាច្រើនមិនចាំបាច់តម្រូវធ្វើការណាត់ជួបទេ។
- ការដឹកជញ្ជូនគឺដោយឥតគិតថ្លៃ ហើយអាចរកបានទាំងទៅនិងមកពីទីតាំងចាក់ថ្នាំបង្ការមួយចំនួន។ មនុស្សដែលមិនអាចធ្វើដំណើរចេញពីផ្ទះអាចស្នើសុំការចាក់ថ្នាំបង្ការនៅតាមផ្ទះបាន។

មិនតម្រូវចាំបាច់មានធានារ៉ាប់រងសុខភាពនោះទេ។ អ្នកមិនចាំបាច់ត្រូវជាពលរដ្ឋអាមេរិក ហើយអ្នកនឹងមិនត្រូវបានសួរអំពីស្ថានភាពអន្តោប្រវេសន៍ដែរ។

## វិធីងាយៗ 2 ក្នុងការទទួលការចាក់ថ្នាំបង្ការនៅខោនធី Los Angeles៖

អ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នក អាចធ្វើការណាត់ជួប ឬរកទីតាំងដែលអ្នកមិនចាំបាច់ត្រូវការធ្វើការណាត់ជួបដោយ៖

1. សូមចូលទៅកាន់គេហទំព័រនេះ៖ **VaccinateLACounty.com** ហើយចុចលើ “**របៀបទទួលការចាក់ថ្នាំបង្ការ**”។ ចូរប្រើមុខងារស្វែងរកដើម្បីរកទីតាំង រកមើលប្រភេទថ្នាំបង្ការណាមួយដែលត្រូវបានផ្ដល់ជូន និងព័ត៌មានច្រើនទៀត។

**ឬក៏**

2. ឬទូរស័ព្ទទៅ**មជ្ឈមណ្ឌលចាក់ថ្នាំបង្ការ**តាមរយៈលេខ **833-540-0473**។ ខ្សែទូរស័ព្ទបើកបម្រើជូនជារៀងរាល់ថ្ងៃចាប់ពីម៉ោង 8 ព្រឹកដល់ 8:30 យប់។ អ្នកអាចស្នើសុំការដឹកជញ្ជូន ឬការមកផ្ដល់សេវាតាមផ្ទះនៅទីនេះ។



អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ដែលបម្រើការជូន 24 ម៉ោងក្នុងមួយសប្ដាហ៍ (24/7) និងមានព័ត៌មានជាច្រើនភាសា។









## សម្រាប់មនុស្សអាយុ 12 ដល់ 17 ឆ្នាំ គឺផ្ដល់ជូនតែថ្នាំបង្ការប្រភេទ Pfizer តែប៉ុណ្ណោះ។

មនុស្សដែលមានអាយុក្រោម 12 ឆ្នាំមិនទាន់អាចចាក់ថ្នាំបង្ការជំងឺ COVID-19 បានទេនៅពេលនេះ។



- **នៅតាមទីតាំងដែលដំណើរការដោយសុខភាពសាធារណៈ អនីតិជនត្រូវការមានការយល់ព្រមពីឪពុកម្ដាយ ឬ**អាណាព្យាបាល ហើយមនុស្សគ្រប់គ្នាត្រូវការយកភ័ស្តុតាងបញ្ជាក់ពីអាយុមកជាមួយ (*មិនចាំបាច់ជាអត្តសញ្ញាណសម្គាល់ដែលចេញដោយរដ្ឋាភិបាលនោះទេ*)។
- សម្រាប់ទីតាំងដែលគ្រប់គ្រងដោយអង្គការផ្សេងទៀត សូមពិនិត្យមើលការយល់ព្រមរបស់ឪពុកម្ដាយ/អាណាព្យាបាល និងតម្រូវការផ្សេងទៀតសម្រាប់ទីតាំងនោះឱ្យបានច្បាស់លាស់។

**VaccinateLACounty.com**
7/27/21 (Cambodian)
County of Los Angeles Public Health